# បរយាយប័ណ្ណឱសថ
# លនដាខាលស៍ កាប់ស៊ុលទន់

# LINDACALS

**I. រូបភាពឱសថ** :
-ជាឱសថប្រភេទកាប់ស៊ុលទន់សំរាប់លេប
-១ប្រអប់មាន ៣បន្ទះ ក្នុង១បន្ទះមាន ១០កាប់ស៊ុលទន់

**II.សមាសធាតុផ្សំ** :
ក្នុង ១កាប់ស៊ុលទន់ មាន៖
-Alfacalcidol…………………………….....0.25 mcg
-Elemental Calcium……………………….....200 mg

**III.គុណភាពព្យាបាល** :
ឱសថនេះប្រើសំរាប់ព្យាបាលជំងឺឆ្អឹងដូចខាងក្រោម៖
-ជំងឺពុកឆ្អឹង
-ជំងឺឆ្អឹងដែលកើតឡើងដោយសារតែតម្រងនោមមិនអាចរក្សាបាននូវកំរិតជាតិកាល់ស្យូមនិងផូស្វ័រគ្រប់គ្រាន់ក្នុងឈាម
-ជំងឺថយចុះកំរិតអ័រម៉ូនប៉ារ៉ាទីរ៉ូអ៊ីត
-ជំងឺកើនឡើងកំរិតអ័រម៉ូនប៉ារ៉ាទីរ៉ូអ៊ីត (ដោយសារជំងឺឆ្អឹង)
-ជំងឺឆ្អឹង Rickets ដោយសារកង្វះជាតិវីតាមីន D កាល់ស្យូម ឬផូស្វ័រ
-ជំងឺឆ្អឹងស្តោត
-ជំងឺខ្សោយតំរងនោមរ៉ាំរ៉ៃ
-ស្ថានភាពដែលទាក់ទងជាមួយនឹងការកើនឡើងកំរិតជាតិអាស៊ីតក្នុងក្រពះ

**IV.ការហាមប្រើ** :
ហាមប្រើឱសថនេះក្នុងករណីដូចខាងក្រោម៖
-ចំពោះអ្នកមានប្រតិកម្មជាមួយនឹងសារធាតុសកម្មណាមួយ ឬជាមួយនឹងសារធាតុផ្សំណាមួយនៃឱសថនេះ
-ចំពោះអ្នកមានជំងឺលើសកំរិតជាតិកាល់ស្យូមក្នុងឈាម
-ចំពោះអ្នកមានជំងឺលើសកំរិតជាតិផូស្វ័រក្នុងឈាម ឬជាតិម៉ាញ៉េស្យូមក្នុងឈាម
-ចំពោះអ្នកមានជំងឺដុំក្រួសក្នុងតម្រងនោម
-ចំពោះអ្នកជំងឺមានសភាពគ្រួសក្នុងតម្រងនោម
-ចំពោះអ្នកជំងឺមានរោគសញ្ញាលើសកំរិតជាតិអាស៊ីតខ្លាំងក្នុងក្រពះ (Zollinger's Ellison Syndrome)
-ចំពោះអ្នកជំងឺដែលកំពុងព្យាបាលដោយប្រើឱសថ digoxin

**V.ការប្រុងប្រយ័ត្ន** :
ឱសថនេះត្រូវមានការប្រុងប្រយ័ត្នចំពោះល័ក្ខខ័ណ្ឌដូចខាងក្រោម៖
-Alfacalcidol បង្កើនការស្រូបចូលទៅក្នុងពោះវៀននូវសារធាតុកាល់ស្យូម និង ផូស្វ័រដូច្នេះត្រូវពិនិត្យកំរិតជាតិកាល់ស្យូម និង ផូស្វ័រក្នុងឈាមឲ្យបានទៀងទាត់ ជាពិសេសចំពោះអ្នកជំងឺខ្សោយតម្រងនោម។
-ប្រសិនបើកំរិតជាតិកាល់ស្យូមកើនឡើងក្នុងឈាម ឬ ក្នុងទឹកនោមកើតឡើងក្នុងអំឡុងពេលប្រើឱសថនេះ ត្រូវបញ្ឈប់ការព្យាបាល ហើយត្រូវរងចាំរហូតទាល់តែកំរិតកាល់ស្យូមក្នុងឈាមវិលមករកសភាពធម្មតាវិញ។ បន្ទាប់មកឱសថ Lindacals ត្រូវចាប់ផ្តើមប្រើឡើងវិញដោយប្រើពាក់កណ្តាលនៃកំរិតដែលបានប្រើចុងក្រោយ ឬប្រើកំរិតដែលអ្នកជំងឺអាចប្រើបាន។
-ឱសថ Lindacals ត្រូវប្រើដោយប្រុងប្រយ័ត្នចំពោះ អ្នកជំងឺដែលលើសកំរិតជាតិកាល់ស្យូមក្នុងឈាម ជាពិសេសអ្នកដែលមានប្រវត្តិកើតជំងឺគ្រួសក្នុងតម្រងនោម។
-មិនត្រូវប្រើឱសថនេះលើសកំរិតណែនាំ
-មិនត្រូវប្រើឱសថនេះហួសកាលបរិច្ឆេទប្រើប្រាស់
❖ចំពោះស្ត្រីមានផ្ទៃពោះ៖
-មិនមានភស្តុតាងគ្រប់គ្រាន់ពីសុវត្ថិភាពនៃការប្រើ alfacalcidol និង calcium carbonate ក្នុងអំឡុងពេលមានផ្ទៃពោះទេ។ ដូចឱសថផ្សេងទៀងដែរ ឱសថ alfacalcidol អាចប្រើបានក្នុងអំឡុងពេលមានផ្ទៃពោះប្រសិនបើការព្យាបាលមានភាពចាំបាច់និងគ្មានជម្រើសណាល្អផ្សេងជាងការប្រើឱសថនេះ។
❖ចំពោះស្ត្រីបំបៅដោះកូន៖
-Alfacalcidol ទំនងជាអាចជ្រាបចូលទៅក្នុងទឹកដោះរបស់ម្តាយ ហើយដែលអាចមានឥទ្ធិពលលើមេតាបូលីសកាល់ស្យូមរបស់ ទារកដែលបៅដោះម្តាយ។
ដូច្នេះជាការល្អប្រសើរ ស្ត្រីជាម្តាយគួរផ្អាកការបំបៅដោះកូនក្នុង អំឡុងពេលប្រើឱសថនេះ។
-មិនមានការហាមប្រើចំពោះការប្រើ calcium carbonate ចំពោះស្ត្រីមានផ្ទៃពោះទេ។
❖ឥទ្ធិពលលើសមត្ថភាពបើកបរ និងការបញ្ជាគ្រឿងម៉ាស៊ីន៖
-Lindacals មិនមានឥទ្ធិពលលើសមត្ថិភាពបើកបរ ឬការបញ្ជាគ្រឿងម៉ាស៊ីនទេ។
❖ផលរំខាន៖
-កើនឡើងកំរិតជាតិកាល់ស្យូមក្នុងឈាមចំពោះអ្នកជំងឺខ្សោយតំរងនោម
-កើនឡើងកំរិតជាតិផូស្វ័រក្នុងឈាម
-ទល់លាមក
-កើនឡើងកំរិតអាល់កាឡាំងក្នុងឈាម
❖អន្តរកម្មឱសថ៖
គួរជៀសវាងប្រើរួមបញ្ចូលគ្នាក្នុងពេលតែមួយជាមួយឱសថដូចខាងក្រោម៖
-Digitalis Glycosides
-Anticonvulsants: Barbiturates
-Mineral oil, cholestyramine, colestipol, sucralfate, antacids (aluminium)
-Antacids (magnesium)

-Digitalis Glycosides
-Anticonvulsants: Barbiturates
-Mineral oil, cholestyramine, colestipol, sucralfate, antacids (aluminium)
-Antacids (magnesium)
-Thiazides
-Vitamin D
-Tetracycline, ciprofloxacin
❖ការរក្សាទុក៖
-ត្រូវទុកនៅសីតុណ្ហភាពក្រោម ៣០°C
-ត្រូវទុកកុំឲ្យត្រូវកំដៅថ្ងៃ និងសំណើម
-ត្រូវទុកឲ្យផុតពីដៃកូនក្មេង។

**VI.កំរិត និងរបៀបប្រើ** :
❖របៀបប្រើ៖
-ឱសថនេះប្រើលេបតាមមាត់។
-មិនត្រូវទំពារ ឬបៀមថ្នាំនេះទេ។
❖កំរិតប្រើ៖
-កំរិតប្រើនៃឱសថ Lindacals គឺអាស្រ័យទៅតាមតម្រូវការរបស់អ្នកជំងឺ។
-កំរិតចាប់ផ្តើមប្រើនៃឱសថនេះគឺ៖
+ចំពោះមនុស្សពេញវ័យ៖ លេប ១ ទៅ ២កាប់ស៊ុល ក្នុង១ថ្ងៃ។
+ចំពោះអ្នកជំងឺមនុស្សចាស់៖ លេប ១ កាប់ស៊ុល ក្នុង១ថ្ងៃ។
+បើទោះបីជាកំរិតប្រើជាក់លាក់សំរាប់ព្យាបាលជំងឺពុកឆ្អឹងគឺ មិនត្រូវបានកំណត់ មានការសិក្សាគ្លីនិកជាច្រើនបានប្រើ Alfacalcidol ក្នុងកំរិតចន្លោះពី 0.5 ទៅ 1mcg ក្នុង១ថ្ងៃ ដោយប្រើ ឬមិនប្រើជាមួយ calcium ក្នុងការព្យាបាលជំងឺ ពុកឆ្អឹង។
+មិនមានកំរិតណែនាំឲ្យប្រើចំពោះកូនក្មេងទេ។
+កំរិតប្រើបន្តបន្ទាប់មកទៀងគឺអាស្រ័យទៅតាមការឆ្លើយតបគ្លីនិករបស់អ្នកជំងឺដើម្បីជៀសវាងការកើនឡើងកំរិតជាតិកាល់ស្យូមក្នុងឈាម។
+ចំពោះមនុស្សពេញវ័យភាគច្រើនឆ្លើយតបទៅនឹងកំរិតប្រើ 1ទៅ 3mcgនៃ alfacalcidol ក្នុង១ថ្ងៃ និង0.25 ទៅ3gm នៃ calcium carbonate ក្នុង១ថ្ងៃ។
➢មុននឹងប្រើឱសថនេះ ត្រូវពិគ្រោះជាមួយគ្រូពេទ្យ ឬឱសថការី។

**VII.លេខបញ្ជិកា** : CAM N 1163IP-17

**VIII.ផលិតដោយ** : Renown Pharmaceuticals Pvt., Ltd. (India)
បានបកប្រែ និងត្រួតពិនិត្យដោយនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង។